# បុគ្គលិកបង្គម

**តើអ្នកចាប់អារម្មណ៍ក្នុងការផ្តល់សេវាសង្គមប្រកបដោយគុណភាព ទៅឲ្យកុមារ/យុវវ័យ គ្រួសារនិងសហគមន៍ដែរឬទេ? តើអ្នកចង់ធ្វើការជាមួយក្រុមអ្នកជំនាញ ដែលផ្តល់នូវសេវាសង្គមប្រកបដោយគុណពភាពខ្ពស់ដែរឬទេ? សូមចូលរួមជាមួយយើង!**

អ្នកនឹងចូលរួមជាមួយក្រុមការងាររបស់អង្គការមិត្តសំឡាញ់ ដែលមានអ្នកជំនាញជិត ៣០០នាក់ ធ្វើការជាមួយគ្នា ដើម្បីផ្តល់នូវសេវាសង្គមជាច្រើនទៅដល់កុមារ និងយុវវ័យដែលបាត់បង់ឱកាស និងក្រុមគ្រួសាររបស់ពួកគេ។ យើងបានបង្កើតវិធីសាស្ត្ររួមមួយចំនួន ដើម្បីគាំទ្រឲ្យកុមារត្រឡប់ទៅរស់នៅជាមួយក្រុមគ្រួសារ និងបន្តការសិក្សារបស់ពួកគេវិញ ធានាក្នុងការផ្តល់ការបណ្តុះបណ្តាលជំនាញ ឬការងារទៅដល់យុវវ័យ រួមទាំងការគាំទ្រគ្រួសារ និងសហគមន៍ ក្នុងការជួយថែទាំកូនរបស់គាត់។ យើងបានផ្តល់ការបណ្តុះបណ្តាលដល់យុវជនលើជំនាញជាច្រើនដូចជា ចុងភៅ សេវាកម្មជួសជុលម៉ូតូ សម្អាងកាយ ជាងកាត់សក់ ជាងផ្សា ផ្នែកអគ្គីសនី ផ្នែកកាត់ដេរ និងការបណ្តុះបណ្តាលដើម្បីបង្កើតចំណូលដល់អាណាព្យាបាល។

**តើអ្នកត្រូវធ្វើអ្វីខ្លះ?**

ជា **បុគ្គលិកសង្គម** អ្នកនឹងទទួលខុសត្រូវលើការផ្តល់ការគាំទ្រ និងសេវាសង្គមនានាឲ្យកុមារនិងយុវវ័យ ដើម្បីឲ្យប្រាកដថាពួកគេស្ថិតក្នុងបរិយាកាសរស់នៅបែបគ្រួសារ កុមារត្រូវបានត្រឡប់ទៅរៀន ឬនៅតែបន្តការរៀនសូត្រនៅសាលា ហើយអ្នកថែទាំ(Care Taker) ត្រូវបានគាំទ្រដើម្បីទទួលបានការងារ ឬអាជីវកម្មផ្ទាល់ខ្លួន។

**តួនាទីជាបុគ្គលិកសង្គម អ្នក នឹងទទួលខុសត្រូវលើការងារដូចខាងក្រោមៈ**

- ធ្វើសមាហរណកម្ម កុមារ នឹងយុវវ័យ ដែលត្រូវគេបោះបង់ចោល ឬកំព្រា ទៅកាន់គ្រួសារចិញ្ចឹមប្រកបដោយសុវត្ថិភាព(ស្របតាមស្តង់ដារកំណត់)
- ស្វែងរក និងជ្រើសរើសគ្រួសារចិញ្ចឹម ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់
- តាមដានជាប្រចាំ ដើម្បីធានានូវសុខមាលភាព និងសុវត្ថិភាពកុមារ យុវវ័យ និងគ្រួសារ
- បង្កើតទំនាក់ទំនងដ៏រឹងមាំ និងទុកចិត្ត ជាមួយក្រុមគោលដៅ អាជ្ញាធរ និងដៃគូពាក់ព័ន្ធ
- រៀបចំ និងអនុវត្ត និតិវិធីសុំកូនពេញលិញក្នុងស្រុកស្របតាមច្បាប់
- រៀបចំផែនការសមាហរណកម្មប្រចាំឆ្នាំ ដោយសហការជាមួយក្រុមការងារ
- ផ្តល់សេវាសង្គមចាំបាច់នានាឲ្យបានទាន់ពេលវេលា ទៅឲ្យកុមារ យុវវ័យ និងគ្រួសារ

**អ្នកត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមៈ**

- អ្នកជាបុគ្គលិកដែលឯករាជ្យ និងស្វាហាប់ មានឆន្ទៈក្នុងការផ្តល់សេវាសង្គម ការការពារកុមារ និងចុះធ្វើការផ្ទាល់នៅសហគមន៍
- អ្នកមានបទពិសោធន៍ធ្វើការងារសង្គម នឹងអាចធ្វើការជាមួយកុមារ យុវវ័យ គ្រួសារដែលបាត់ឱកាស និងសហគមន៍របស់ពួកគេបានយ៉ាងប្រសើរ
- អ្នកមានចំណេះដឹងសង្គមសាស្ត្រ និងចិត្តសាស្ត្រ
- អ្នកមានទំនុកចិត្តក្នុងការធ្វើការទំនាក់ទំនង និងសហការ ជាមួយអជ្ញាធរ និងស្ថាប័នពាក់ព័ន្ធនឹងដំណើរការសុំកូន
- អាចនិយាយ និងសរសេរភាសាអង់គ្លេសបាន
- អ្នកមានចំណេះដឹងក្នុងការប្រើប្រាស់កុំព្យូទ័រ(Microsoft Word, Excel…)

**តាំងការងារ៖ រាជធានីភ្នំពេញ និងធ្វើដំណើរទៅខេត្តញ៉ឹកញាប់**

បេក្ខជនដែលមានចំណាប់អារម្មណ៍ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សូមផ្ញើពាក្យសុំ និងប្រវត្តិរូបសង្ខេប (CV and Cover Letter) មកកាន់ទីស្នាក់ការអង្គការមិត្តសំឡាញ់ តាមអាសយដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជ ធានីភ្នំពេញ (ខាងជើងសារមន្ទីរជាតិ) ឬ អ៊ីម៉ែល hr@mithsamlanh.org។ សូមបញ្ជាក់ពីប្រាក់បៀវត្ស រំពឹងទុក និងតួនាទី ដែលអ្នកដាក់ពាក្យ ។

ការជ្រើសរើសនឹងត្រូវបានធ្វើឡើងប្រកបដោយតម្លាភាព។

បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹង ត្រូវបានទំនាក់ទំនងមកធ្វើការម្ភាសន៍។
បេក្ខជនដែលជោគជ័យនឹងត្រូវបានតម្រូវឲ្យ គោរពតាមគោលការណ៍ ការពារកុមាររបស់អង្គការមិត្តសំឡាញ់។

**ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៨។**